ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**អគ្គនាយកដ្ឋានអាស៊ាន**

សេចក្ដីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយដៃគូសន្ទនា និង កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូកបីលើកទី២៤

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ - **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ជាមួយដៃគូសន្ទនាអាស៊ាន រួមមាន ឥណ្ឌា នូវែលសេឡង់ អូស្ត្រាលី ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ សហភាពអឺរ៉ុប កាណាដា និងចក្រភពអង់គ្លេស និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូកបីលើកទី២៤ នៅរដ្ឋធានីហ្សាការតា នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣។

ក្នុងឋានៈកម្ពុជាជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-រុស្ស៊ី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានធ្វើជាសហប្រធាន ជាមួយ **ឯកឧត្តម ស៊ែរជេ ឡាវរ៉ូហ្វ** (Sergey Lavrov) រដ្ឋមន្ត្រីការបរទេសនៃសហព័ន្ធរុស្ស៊ី នៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាន រួមមានការប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន បញ្ហាទាក់ទងនឹងសន្តិសុខបច្ចេកវិទ្យា ព័ត៌មាននិងគមនាគមន៍ និងសន្តិសុខតាមប្រព័ន្ធអ៊ីនធើណែត តាមរយៈការចែករំលែកព័ត៌មាន និងវិធានការកសាងសមត្ថភាពដែលមានគោលដៅល្អផ្សេងទៀត។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ពីសារៈសំខាន់ ដើម្បីពន្លឿនការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនទីបង្ហាញផ្លូវនៃកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-រុស្ស៊ី ដែលបានកែសម្រួល និងកម្មវិធីការងារ ឆ្នាំ២០២១-២០២៥ និងរាល់សកម្មភាពអាទិភាពសំខាន់ៗផ្សេងទៀត ក្រោមកម្មវិធីកិច្ចសហប្រតិបត្តិការអាស៊ាន-សហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី ឆ្នាំ២០២០-២០២៥។ កិច្ចប្រជុំបានអនុម័តសេចក្ដីប្រកាសរួមនៃរដ្ឋមន្ត្រីការបរទេសអាស៊ាននិងរុស្ស៊ី ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៥ នៃទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-រុស្ស៊ី។

អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ឥណ្ឌា៖</u>**

អាស៊ានស្វាគមន៍ការចូលរួមរបស់ឥណ្ឌាក្នុងតំបន់ តាមរយៈគោលនយោបាយឆ្ពោះមកទិសខាងកើត និងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ឥណ្ឌា និងបានកោតសរសើរពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាព ដើម្បីអនុវត្តភាពជាដៃគូអាស៊ាន-ឥណ្ឌា សម្រាប់សន្តិភាព វឌ្ឍនភាព និងវិបុលភាពរួម (ឆ្នាំ២០២១-២០២៥)។ រដ្ឋមន្ត្រីការបរទេសបានអនុម័តឧបសម្ព័ន្ធបន្ថែមលើផែនការសកម្មភាព ដែលជាការតាមដានការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ឥណ្ឌាកាលពីឆ្នាំមុន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានទទ្ទឹងរង់ចាំការបញ្ចប់និងដំណើរការទាន់ពេលវេលារបស់ផ្លូវល្បឿនលឿនត្រីភាគី ឥណ្ឌា-មីយ៉ាន់ម៉ា-ថៃ និងលទ្ធភាពនៃការពង្រីកផ្លូវនេះមកកាន់ប្រទេសឡាវ កម្ពុជា និងវៀតណាមផងដែរ។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-នូវែលសេឡង់៖</u>**

អាស៊ានបានបង្ហាញពីការកោតសរសើរចំពោះការបន្តគាំទ្ររបស់នូវែលសេឡង់លើមជ្ឈភាពអាស៊ាន នៅក្នុងនិម្មាបនកម្មតំបន់ដែលកំពុងវិវត្ត តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងយន្តការដែលដឹកនាំដោយអាស៊ាននានា។ កិច្ចប្រជុំបានអនុម័តសេចក្តីប្រកាសរួមអាស៊ាន-នូវែលសេឡង់ ស្តីពីកិច្ចសហប្រតិបត្តិការលើទស្សនវិស័យអាស៊ានស្តីពី ឥណ្ឌូ-ប៉ាស៊ីហ្វិក និងទទ្ទឹងរង់ចាំការចុះហត្ថលេខាលើពិធីសារលើកទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងបង្កើតពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) នៅខែសីហា ឆ្នាំ២០២៣។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកទឹកចិត្តនូវែលសេឡង់ផ្តល់ការគាំទ្របន្ថែមទៀត ចំពោះសហគ្រាសមីក្រូធុនតូច និងមធ្យមពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ឱ្យកាន់តែរឹងមាំ មានភាពប្រកួតប្រជែង និងអាចសម្របតាមបដិវត្តន៍ឧស្សាហកម្មទី៤ រួមមានតាមរយៈការអនុវត្តផែនការការងារទី៤។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-អូស្ត្រាលី៖</u>**

អាស៊ានបានកោតសរសើរចំពោះវឌ្ឍនភាពគន្លឹះសំខាន់ៗ ដែលបានផ្តល់ជូនក្រោមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-អូស្ត្រាលី (CSP) តាមរយៈកញ្ចប់នៃគំនិតផ្តួចផ្តើមអូស្ត្រាលីសម្រាប់អាស៊ាន (Aus4ASEAN) រួមមាន គំនិតផ្តួចផ្តើមស្តីពី អូស្ត្រាលីដើម្បីអនាគតអាស៊ាន (Aus4ASEAN Futures Initiatives) ដែលមានទឹកប្រាក់ចំនួន ២០៤លានដុល្លារអូស្ត្រាលី កម្មវិធីអាហារូបករណ៍ (Aus4ASEAN) ចំនួន១០០កន្លែង និងគំនិតផ្តួចផ្តើមអូស្ត្រាលី ដើម្បីធ្វើបរិវត្តកម្មឌីជីថល និងអនាគតជំនាញអាស៊ាន។ កិច្ចប្រជុំក៏បានទទ្ទឹងរង់ចាំនូវការរៀបចំកិច្ចប្រជុំកំពូលពិសេសដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៥០ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-អូស្ត្រាលី ដែលនឹងប្រព្រឹត្តទៅនៅខែមីនា ឆ្នាំ២០២៤ នៅប្រទេសអូស្ត្រាលី ដែលនឹងបង្កើតបានជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយបន្ថែមទៀត នៃភាពជាដៃគូសន្ទនាអាស៊ាន-អូស្ត្រាលី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានទទួលស្គាល់ថា AANZFTA បានផ្តល់ផលប្រយោជន៍យ៉ាងធំធេងដល់ប្រជាជនរបស់អាស៊ាន

និងអូស្ត្រាលី និងបានអះអាងសារជាថ្មីពីសារៈសំខាន់ នៃការចុះហត្ថលេខាលើពិធីសារលើកទី២ ដើម្បីធ្វើវិសោធនកម្មដំឡើងកម្រិតកិច្ចព្រមព្រៀងនេះ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា មានភាពស៊ីសង្វាក់គ្នាសំខាន់ៗរវាងផែនការមេស្តីពី ការតភ្ជាប់អាស៊ាន ឆ្នាំ២០២៥ និងកម្មវិធីអូស្ត្រាលីដើម្បីអនាគតអាស៊ានស្តីពី សេដ្ឋកិច្ចនិងការតភ្ជាប់ និងគំនិតផ្តួចផ្តើមភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន៖</u>**

ដោយផ្អែកលើមូលដ្ឋានរឹងមាំនៃភាពជាដៃគូយុទ្ធសាស្ត្រទូលំទូលាយអាស៊ាន-ចិន ដែលបានបង្កើតឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០២១ កិច្ចប្រជុំបានអះអាងសាជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការទំនាក់ទំនងស៊ីជម្រៅបន្ថែមទៀត និងបានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការបន្តជំរុញភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ចិន ដើម្បីរក្សាភាពជាដៃគូប្រកបដោយថាមពល ខ្លឹមសារ និងផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ អាស៊ានបានថ្លែងអំណរគុណចំពោះការគាំទ្ររបស់ចិន ចំពោះមជ្ឈភាពអាស៊ាននៅក្នុងនិម្មាបនកម្មតំបន់ដែលកំពុងវិវត្ត និងបានរំឭកថា ចិនគឺជាដៃគូសន្ទនាដំបូងគេមួយក្នុងចំណោមដៃគូសន្ទនាអាស៊ាន ដែលបានចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) កាលពីខែតុលា ឆ្នាំ២០០៣។ ក្នុងស្មារតីនេះ កិច្ចប្រជុំបានអនុម័តសេចក្តីប្រកាសរួមស្តីពី ការអបអរសាទរនិងឆ្លុះបញ្ចាំងពីខួបអនុស្សាវរីយ៍លើកទី២០ នៃការចូលជាភាគីនៃ TAC របស់ចិន។ ដោយមានការប្តេជ្ញាចិត្តរួមគ្នាក្នុងការធ្វើឱ្យអាស៊ានក្លាយជាចំណុចស្នូលនៃកំណើន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់ពីសារៈសំខាន់នៃការបញ្ចប់ការចរចាលើកកម្រិតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០ (ACFTA 3.0) និងការចូលជាធរមាននាពេលថ្មីៗនេះនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចតំបន់គ្រប់ជ្រុងជ្រោយ (RCEP)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបង្ហាញពីការគាំទ្ររបស់កម្ពុជាចំពោះសេចក្តីប្រកាសរួមស្តីពី កិច្ចសហប្រតិបត្តិការផ្តល់ប្រយោជន៍ទៅវិញទៅមករវាងគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ និងទស្សនវិស័យអាស៊ានស្តីពី ឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលនឹងត្រូវអនុម័តនៅក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី២៦ នៅខែកញ្ញា ឆ្នាំ២០២៣។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសសមាជិកអាស៊ាននិងចិន ក្នុងការបញ្ចប់ការពិនិត្យពិភាក្សាជុំទី២ នៃសេចក្តីព្រាងអត្ថបទចរចាតែមួយស្តីពី ក្រមប្រតិបត្តិនៅក្នុងសមុទ្រចិនខាងត្បូង។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ជប៉ុន៖</u>**

កិច្ចប្រជុំបានអបអរសាទរឆ្នាំទី៥០ នៃមិត្តភាព និងកិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន និងទន្ទឹងរង់ចាំការប្រកាសជាភាពជាដៃយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុន នៅកិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២៦ នៅខែកញ្ញា ក៏ដូចជាការរៀបចំកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ជប៉ុន នៅខែធ្នូ ឆ្នាំ២០២៣ នៅទីក្រុងតូក្យូ។ អាស៊ានបានស្វាគមន៍ការគាំទ្ររបស់ជប៉ុន

ចំពោះ AOIP និងបានកោតសរសើរចំពោះការរួមចំណែករបស់ជប៉ុននូវថវិកាចំនួន ១០០លានដុល្លារ សម្រាប់ការបង្កើតមូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន (JAIF) ៣.០ ក្នុងខែមីនា ឆ្នាំ ២០២៣ ដែលគាំទ្រដល់គំនិតផ្តួចផ្តើមជាក់ស្តែងក្រោម AOIP។ ក្នុងកិច្ចប្រជុំនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា អាស៊ាន និងជប៉ុន គួរធ្វើកិច្ចការជាមួយគ្នាដើម្បីអនុវត្តភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ និងជំរុញកិច្ចសហប្រតិបត្តិការក្នុងការកសាងសមត្ថភាពសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងការបង្កើតកាលានុវត្តភាពធុរកិច្ចថ្មីៗ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីអាទិភាពសំខាន់ចំនួនពីររបស់ឥណ្ឌូ-ប៉ាស៊ីហ្វិកសេរី និងបើកចំហ (FOIP) ដែលអាស៊ាននិងជប៉ុនគួរពិចារណាក្នុងការជំរុញទៅមុខ៖ (១) ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជាកំពង់ផែ ផ្លូវដែក ថាមពល និង ICT និង (២) ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជនដ៏រឹងមាំ ដើម្បីប្រមូលធនធានដើម្បីបំពេញតម្រូវការរបស់អាស៊ាន។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សាធារណរដ្ឋកូរ៉េ៖</u>**

កិច្ចប្រជុំបានស្វាគមន៍ការប្តេជ្ញាចិត្តរបស់សាធារណរដ្ឋកូរ៉េ ចំពោះតំបន់មួយដែលប្រកបដោយសន្តិភាព ស្ថិរភាព និងវិបុលភាព តាមរយៈការពង្រឹងចំណុចបំពេញបន្ថែមរវាងយុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក និង AOIP និងបានទទួលរង់ចាំការអនុម័តនៃសេចក្តីប្រកាសរួមស្តីពី កិច្ចសហប្រតិបត្តិការ AOIP នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េលើកទី២៤ ក្នុងខែកញ្ញាខាងមុខនេះ។ អាស៊ានបានស្វាគមន៍បំណងរបស់សាធារណរដ្ឋកូរ៉េ ក្នុងការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ នៅក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៣៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សាធារណរដ្ឋកូរ៉េ នៅឆ្នាំ២០២៤។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់សាធារណរដ្ឋកូរ៉េ ក្នុងការជំរុញឱ្យមានកិច្ចសហប្រតិបត្តិការដែលប្រកបដោយអត្ថន័យ ខ្លឹមសារ និងផ្តល់សារប្រយោជន៍ទៅវិញទៅមក តាមរយៈក្រោមគំនិតផ្តួចផ្តើមសាមគ្គីភាពសាធារណរដ្ឋកូរ៉េ-អាស៊ាន (KASI)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់របស់ពាណិជ្ជកម្មសេរីនិងបើកចំហ ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ចតំបន់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្នើថា អាស៊ាននិងសាធារណរដ្ឋកូរ៉េ ចាំបាច់ត្រូវទាញយកប្រយោជន៍ឱ្យបានពេញលេញលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគីនានា រួមមានភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប៖</u>**

កិច្ចប្រជុំបានរំឭកឡើងវិញពីការរៀបចំកិច្ចប្រជុំកំពូលអបអរសាទរខួបអនុស្សាវរីយ៍អាស៊ាន-សហភាពអឺរ៉ុបប្រកបដោយជោគជ័យ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ នៅទីក្រុងព្រុចសែល និងបានលើកទឹកចិត្តភាគីទាំងពីរសម្រេចឱ្យបាននូវគោលដៅ និងគោលបំណងដែលបានចែងនៅក្នុងសេចក្តីប្រកាសរួមរបស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-

សហភាពអឺរ៉ុបឆ្នាំ២០២២។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានទទួលស្គាល់នូវវឌ្ឍនភាពជាវិជ្ជមាន នៅក្នុងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគីរវាងសហភាពអឺរ៉ុប និងប្រទេស សមាជិកអាស៊ានមួយចំនួន និងបានស្នើអាស៊ាននិងសហភាពអឺរ៉ុប ធ្វើកិច្ចការឆ្ពោះទៅរកការ សម្រេចឱ្យបាននូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងតំបន់និងតំបន់ (a region-to-region FTA) ដែលជាគោលបំណងរយៈពេលវែងរួមមួយ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងឡើង ពីសារៈសំខាន់ដ៏ធំធេញនៃការតភ្ជាប់តំបន់ និងបានជំរុញឱ្យសហភាពអឺរ៉ុបបន្តជំរុញការវិនិយោគ ផ្ទាល់ពីបរទេស (FDI) លើហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ចឌីជីថល និងទន្ទឹងរង់ចាំដំណើរការ ប្រតិបត្តិការនៃកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសគ្រប់ជ្រុងជ្រោយរវាងអាស៊ាន-សហភាពអឺរ៉ុប ដើម្បីបន្តលើកកម្ពស់ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន និងលំហូរធុរកិច្ចរវាងតំបន់ទាំងពីរ។

***<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-កាណាដា៖</u>***

កិច្ចប្រជុំបានកត់សម្គាល់ពីលទ្ធផលវិជ្ជមាននៃខួបអនុស្សាវរីយ៍លើកទី៤៥ នៃទំនាក់ទំនង កិច្ចសន្ទនាអាស៊ាន-កាណាដាកាលពីឆ្នាំមុន។ កិច្ចប្រជុំបានឯកភាពលើសេចក្តីព្រាងសេចក្តីប្រកាស រួមរបស់ថ្នាក់ដឹកនាំស្តីពី ភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-កាណាដា ដែលនឹងត្រូវអនុម័តនៅក្នុងកិច្ច ប្រជុំកំពូលអាស៊ាន-កាណាដា នៅខែកញ្ញា ឆ្នាំនេះ។ នៅក្នុងកិច្ចប្រជុំ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្នើថា អាស៊ាននិងកាណាដា គួរបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវរាល់វិធានការណ៍ដែលមានចែង ក្នុងសេចក្តីថ្លែងការណ៍រួមស្តីពី ផែនការការងារពាណិជ្ជកម្ម និងវិនិយោគ ឆ្នាំ២០២១-២០២៥ ដើម្បី ជំរុញកំណើន និងផ្តល់ថាមពលឡើងវិញលើខ្សែសង្វាក់ផ្គត់ផ្គង់សកល ក៏ដូចជាការបញ្ចប់ឱ្យទាន់ ពេលវេលាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា។

***<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចក្រភពអង់គ្លេស៖</u>***

អាស៊ានបានស្វាគមន៍ការអនុវត្តរបស់ចក្រភពអង់គ្លេស ចំពោះផែនការសកម្មភាពអាស៊ាន-ចក្រភពអង់គ្លេស ឆ្នាំ២០២២-២០២៦ តាមរយៈកម្មវិធីអាទិភាពទាំង៥ រួមមាន៖ ១) សមាហរណ-កម្មសេដ្ឋកិច្ច ២) ការអប់រំដល់កុមារី ៣) ស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ៤) ប្រព័ន្ធសុខា-ភិបាល និង ៥) ការផ្លាស់ប្តូរអាកាសធាតុ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តចក្រភព អង់គ្លេសពង្រឹងកិច្ចសហប្រត្តិបត្តិការសេដ្ឋកិច្ចជាមួយអាស៊ាន រួមទាំងតាមរយៈសមាហរណកម្ម សេដ្ឋកិច្ចតំបន់ ក៏ដូចជាតាមរយៈលទ្ធភាពដែលអាចមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចក្រភពអង់គ្លេស។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើឱ្យអាស៊ាននិងចក្រភពអង់គ្លេសធ្វើកិច្ចការ ឆ្ពោះទៅរកផែនការគ្រប់ជ្រុងជ្រោយមួយ ដែលគ្របដណ្តប់លើថាមពលស្អាត ការដឹកជញ្ជូនដែល គិតគូដល់បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព និងហិរញ្ញវត្ថុបៃតង សម្រាប់អនាគតដែល គ្មានសារជាតិកាបូន។

**<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូកបីលើកទី២៤៖</u>**

កិច្ចប្រជុំបានគូសបញ្ជាក់ជាថ្មីអំពីតួនាទីដ៏សំខាន់នៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបី ក្នុងការពង្រឹង និងធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចខិតខំប្រឹងប្រែងការកសាងសហគមន៍។ កិច្ចប្រជុំគូសបញ្ជាក់អំពីតម្រូវការជាចាំបាច់ក្នុងការបង្កើនសមត្ថភាព និងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាក្នុងតំបន់ ទាំងពេលបច្ចុប្បន្ននិងពេលអនាគត ដើម្បីជំរុញភាពធន់នៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញឆ្ពោះទៅរកបរិយាប័ន្ន សមធម៌ និងស្ថិរភាពនៃកំណើន។ ពាក់ព័ន្ធនឹងបញ្ហានេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលេចនូវអាទិភាពចំនួន៣ ដែលអាស៊ានបូកបី គួរយកចិត្តទុកដាក់៖ **ទី១** ការពង្រឹងតួនាទីនៃគំនិតផ្តួចផ្តើមឈៀងម៉ៃស្តីពី ពហុភាគីនិយម (CMIM) និងការគាំទ្រការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (AMRO) ដើម្បីរក្សាស្ថិរភាពទីផ្សារហិរញ្ញវត្ថុក្នុងតំបន់ **ទី២** ការពង្រឹងយន្តការនៃការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់អាស៊ានបូកបី ដើម្បីធានាសន្តិសុខស្បៀងនៅក្នុងតំបន់ និង**ទី៣** ការជំរុញវិស័យថាមពលក្នុងក្របខ័ណ្ឌអាស៊ានបូកបី ដើម្បីដោះស្រាយវិបត្តិថាមពលនាពេលបច្ចុប្បន្ន និងការផ្លាស់ប្តូរពីឥន្ធនៈហ្វូស៊ីលទៅជាប្រភពថាមពលជំនួសផ្សេងទៀតដែលអាចប្រើប្រាស់បានក្នុងរយៈពេលវែងប្រកបដោយភាពនវានុវត្តន៍៕